ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
រឿងព្រហ្មទណ្ឌលេខ ១៣២៥
ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ ៥៤២ "ខ"
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាអសាធារណៈនៅសាលាដំបូងខេត្តកំពង់ស្ពឺ នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

- ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣២៥ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១/. ឈ្មោះ [redacted] សុខខួច ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមេការនៅហាងម្លប់ពោធិ៍រំលេចធំ មានទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] គិនហ៊ាង (ស) ម្តាយឈ្មោះ [redacted] ណារ័ង (រ) មេម៉ាយ មានកូន ០៥នាក់ ទោសពីមុន "គ្មាន"។

(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១០៤០ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២)

២/. ឈ្មោះ [redacted] ជាត ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរចុងភៅនៅហាងម្លប់ពោធិ៍រំលេចធំ ទីកន្លែងកំណើតភូ [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ឃឹន (ស) ម្តាយឈ្មោះ [redacted] ទី (រ) មេម៉ាយ មានកូន ០១នាក់ ទោសពីមុន "គ្មាន"។

(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១០៤១ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២)

៣/. ឈ្មោះ [redacted] គន្ធា ហៅ អាម៉ាប់ ភេទស្រី មុខរបរមេការហាងម្លប់ពោធិ៍រំលេចធំ ទីលំនៅបច្ចុប្បន្នភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ (គេចខ្លួន)

ជាប់ចោទពីបទ៖ សញ្ជារកម្ម ប្រព្រឹត្តនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ទីតាំង

ស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៨/. ឈ្មោះ [redacted] **សុងហាក់** ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ស្ពឺ និងទីលំនៅបច្ចុប្បន្ននៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] សៀវផេង (ស) ម្តាយឈ្មោះ [redacted] សាយហ្គិច (រ) ប្រពន្ធឈ្មោះ [redacted] គីមសួរ មានកូន ០២នាក់ ទោសពីមុន -គ្មាន-។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ និងសញ្ជារកម្ម** ប្រព្រឹត្តនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ទីតាំងស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ មាត្រា ២៦ និងមាត្រា ៣២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

-មានលោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted] សុខខួច។

-មានលោកស្រី [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ **យឺន ផាត**។

-មានលោកស្រី [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted] សុងហាក់។

-មានលោក [redacted] ជាមេធាវីការពារក្តីឲ្យជនរងគ្រោះ។

**<u>រឯអង្គហេតុនៃរឿងក្តីមានដូចតទៅ</u>** ៖

កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥-៣៣នាទី កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលខេត្តកំពង់ស្ពឺ បានធ្វើប្រតិបត្តិការបង្ក្រាបករណីផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ និងសញ្ជារកម្ម មួយកន្លែងស្ថិតនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ដែលមានទីតាំងស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឃាត់ខ្លួនជនសង្ស័យ ០២នាក់ មានឈ្មោះ [redacted] **សុខខួច** ភេទស្រី អាយុ ៣៧ឆ្នាំ មុខរបរមេការហាងម្លប់ពោធិ៍រំលេចធំ និងឈ្មោះ [redacted] ផាត ភេទស្រី អាយុ ៣១ឆ្នាំ មុខរបរចុងភៅហាងម្លប់ពោធិ៍រំលេចធំ ហើយជនសង្ស័យចំនួន ០២នាក់ផ្សេងទៀត មានឈ្មោះ [redacted] **គន្ធា** ហៅ **អាម៉ាប់** ភេទស្រី មុខរបរមេការហាងម្លប់ពោធិ៍រំលេចធំ និងម្ចាស់ភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ឈ្មោះ [redacted] សុងហាក់ ភេទប្រុស អាយុ ៣៧ឆ្នាំ បានរត់គេចខ្លួនបាត់។ តាមរយៈលទ្ធផលនៃការអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយរបស់នារីរងគ្រោះ បានបង្ហាញថា ជនសង្ស័យឈ្មោះ [redacted] សុខខួច ឈ្មោះ [redacted] ផាត និងឈ្មោះ [redacted] **គន្ធា** ហៅ **អាម៉ាប់** បានប្រព្រឹត្តអំពើសញ្ជារកម្មចំណែកជនសង្ស័យជាម្ចាស់ភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ឈ្មោះ [redacted] **សុងហាក់** បានផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ និងប្រព្រឹត្តអំពើសញ្ជារកម្ម។

-បានឃើញរបាយការណ៍សំយោគលេខ **១៤២ របក/**២២ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ។



Scanned with CamScanner

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ១៤២ ដ.ស.ព/២៣ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញដីកាដំណោះស្រាយលេខ ១៤៥ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះ **៩៦៩ ដចស.រប/២២** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខខួច** ឆ្លើយថា ខ្លួនបានដឹងអំពីការចោទប្រកាន់របស់តំណាងអយ្យការរួចហើយ ខ្លួនសូមបដិសេធចំពោះចម្លើយនៅសមត្ថកិច្ចចោលទាំងស្រុង។ ខ្លួនស្គាល់ចៅកែហាងម្លប់ពោធិ៍រលេចធំឈ្មោះ [redacted] សុងហាក់ ដោយសារខ្លួនធ្លាប់ជួលផ្ទះរបស់គាត់ ស្ថិតនៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និងចៅកែស្រីឈ្មោះ [redacted] **ធីមសួរ** ភេទស្រី អាយុប្រហែល ៣១ឆ្នាំ រស់នៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ ខ្លួនធ្វើការនៅក្នុងហាងនេះ ខ្លួនបានទទួលប្រាក់ខែចំនួន១៥០(មួយរយហាសិប)ដុល្លាអាមេរិកក្នុងមួយខែ និងទទួលប្រាក់ពីភ្ញៀវខ្លះ សម្រាប់ចិញ្ចឹមកូន និងចំណាយផ្សេងៗក្នុងគ្រួសារ។ ខ្លួនបានចូលធ្វើការនៅហាងម្លប់ពោធិ៍រលេចធំនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ តាមរយៈចៅកែឈ្មោះ [redacted] **សុងហាក់** ដោយខ្លួនជាមេការមើលការខុសត្រូវភ្ញៀវ ដែលចូលមកផឹកស៊ីនៅហាងនោះមានបើកកន្លែងផឹកស៊ី និងបើកផ្ទះសំណាក់ ពេលខ្លួនធ្វើការបានប្រហែលជា២ខែ ចៅកែឈ្មោះ [redacted] **សុងហាក់** និងឈ្មោះ [redacted] **ធីមសួរ** ក៏បានបើកខាំអូខេមួយមុខទៀត ដោយគាត់ឲ្យខ្លួនមេការឈ្មោះ [redacted] គន្ធា ហៅ **អាម៉ាប់** ជាអ្នកមើលការខុសត្រូវ ចំណែកសេវាខាងផ្ទះសំណាក់ចៅកែទាំងពីរជាអ្នកមើលការខុសត្រូវផ្ទាល់ ព្រោះគាត់ស្នាក់នៅក្នុងហាងនោះផ្ទាល់តែម្តង។ នៅហាងនេះមានខាំអូខេចំនួន២បន្ទប់ និងនារីបម្រើការងារចំនួន០៤នាក់។ ពេលខ្លួនធ្វើជាមេការក្នុងហាង គឺមានភ្ញៀវធ្លាប់សួរខ្លួនពីរឿងចង់រួមភេទជាមួយនារីបម្រើការងារនៅក្នុងហាងនោះមែន តែខ្លួនបានប្រាប់គាត់វិញថា ខ្លួនមិនដឹងទេ ទៅនិយាយជាមួយនារីនោះផ្ទាល់ទៅ ខ្លួនមិនពាក់ព័ន្ធទេ ក្រោយមកទៀតខ្លួនក៏មិនដឹងថា គេនិយាយត្រូវគ្នាឬអត់នោះទេ តែដល់ពេលគិតលុយពេលខ្លះខ្លួនឃើញចៅកែគិតទាំងថ្លៃផ្ទះសំណាក់ បញ្ចូលក្នុងបុងម្ហូបអាហារដែរ ទើបខ្លួនដឹងថា ភ្ញៀវបើកបន្ទប់ចូលដេក តែខ្លួនមិនដឹងថាគាត់បើកបន្ទប់ចូលដេកជាមួយអ្នកណានោះទេ។ ក្នុងអំឡុងពេលខ្លួនធ្វើការនៅក្នុងហាងម្លប់ពោធិ៍រលេចធំមិនដែលមាននារីបម្រើការនៅក្នុងហាងប្រាប់ខ្លួនថាគាត់ទៅដេកជាមួយភ្ញៀវក្នុងហាងផ្ទះសំណាក់នោះទេ។ នៅពេលគិតលុយ ខ្លួនឃើញចៅកែគិតលុយថ្លៃបន្ទប់ចំនួន ៣០,០០០រៀល ខ្លួនក៏សួរគាត់ គាត់ក៏បានឆ្លើយថា គិតបន្ថែមថ្លៃបន្ទប់ផ្ទះសំណាក់ដែលភ្ញៀវឲ្យបើកសម្រាប់ដេកជាមួយស្រីតម្លៃ២០,០០០រៀល ប៉ើមានស្រោមអនាម័យបន្ថែម ១០,០០០រៀល។ ខ្លួនដឹងថានៅក្នុងហាងមានលួចបង្កប់សេវាកម្មភ្លូវភេទមែន ព្រោះពេលគិតលុយជូនកាលខ្លួនឃើញចៅកែគិតទាំងថ្លៃបន្ទប់ផ្ទះសំណាក់ ចូលជាមួយបុងម្ហូប តែនេះជាការរកស៊ីរបស់ចៅកែ ឯខ្លួនគ្រាន់តែជាអ្នកស៊ីឈ្នួលគេ ខ្លួនមិនអាចចេះដឹងរឿងការរកស៊ីរបស់ចៅកែទេ។ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០២២ វេលាម៉ោង១៨ និង៣០នាទី ខ្លួនកំពុងមើលភ្ញៀវនៅក្នុងហាង ក៏ស្រាប់តែមានសមត្ថកិច្ចមកដល់ធ្វើការឆែកឆេរក្នុងហាង ឈានដល់ការឃាត់ខ្លួនរូបខ្លួនតែម្តង។ ខ្លួនសូមបញ្ជាក់បន្ថែមថា ខ្លួនសព្វថ្ងៃមានកូន ០៥នាក់ក្នុងបន្ទុក កូនទី១ឈ្មោះ [redacted] សុរស្មី ភេទស្រី អាយុ ១៨ឆ្នាំ, កូនទី២ឈ្មោះ [redacted] **សុរិយា** ភេទស្រី អាយុ ១០ឆ្នាំ (សតិមិនគ្រប់), កូនទី៣ឈ្មោះ [redacted] សុបញ្ញា ភេទប្រុស អាយុ ០៨ឆ្នាំ, កូនទី៤ឈ្មោះ [redacted] **សុរិយា** ភេទប្រុស អាយុ ០៥ឆ្នាំ និងកូនទី៥ឈ្មោះ [redacted] សុដាណា ភេទប្រុស អាយុ ០៣ឆ្នាំ រស់នៅក្រោមការចិញ្ចឹម និងបីបាច់របស់ខ្លួន។



Scanned with CamScanner

- បានឃើញចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជាត ឆ្លើយថា ខ្លួនបានដឹងពីការចោទប្រកាន់របស់តំណាងអយ្យការរួចហើយ។ ខ្លួនចាប់ផ្តើមធ្វើការជាអ្នករត់តុ និងលាងចានចាប់តាំងពីខែតុលា ឆ្នាំ២០២២ ដោយធ្វើចាប់ពីម៉ោង៩ ដល់ម៉ោង១០យប់ បានទទួលប្រាក់ខែ ១៥០ដុល្លាអាមេរិក។ ខ្លួនមិនស្គាល់ឈ្មោះថៅកែហាងម្លប់ពោធិ៍រំលេចធំទេ ប៉ុន្តែពេលខ្លួនចូលធ្វើការនៅទីនោះ មានថៅកែប្រុសស្រីចំនួន០២នាក់ ខ្លួនហៅគាត់ថា ចែ និងបង ព្រោះខ្លួនទើបតែចូលធ្វើការនៅហាងនេះបានរយៈពេលខ្លីប៉ុណ្ណោះ។ ខ្លួនមិនបានដឹងពាក់ព័ន្ធនឹងរឿងសេវាកម្មផ្លូវភេទនោះទេ។ កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១៨រសៀល នៅក្នុងហាងម្លប់ពោធិ៍រំលេចធំ ស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ខ្លួនកំពុងតែលាងចានឆ្នាំនៅខាងក្រោយ រួចមានភ្ញៀវកម្មង់ម្ហូប ខ្លួនបានលើកម្ហូបយកទៅឲ្យរួចក៏ប្រទះឃើញ មានកម្លាំងសមត្ថកិច្ចបានធ្វើការឆែកឆេរ នៅក្នុងហាងម្លប់ពោធិ៍រំលេចធំ ដែលមានមនុស្សចំនួន០៦នាក់ ដោយមានទី១.ខ្លួន ទី២.ឈ្មោះ អាមុី ទី៣.ឈ្មោះ អាសា ទី៤.ឈ្មោះ អាស៊ីម ទី៥.ឈ្មោះ អ័រ និងទី៦.ឈ្មោះ [redacted] សុខខួច មានមុខងារជាអ្នករត់តុ និងអ្នកមើលកញ្ចុះ ហើយធ្វើការឃាត់ខ្លួនរូបខ្លួន និងឈ្មោះ [redacted] សុខខួច បញ្ជូនមកតុលាការខេត្តកំពង់ស្ពឺចាត់ការតាមនីតិវិធីច្បាប់តែម្តង។

- បានឃើញចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុងហាក់ ឆ្លើយថា ខ្លួនអាចឆ្លើយដោយខ្លួនឯងបានដោយមិនចាំបាច់មានមេធាវីការពារសិទ្ធិទេ។ ខ្លួនបានដឹងពីការចោទប្រកាន់របស់តំណាងអយ្យការរួចហើយ។ ប៉ុន្តែខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ខ្លួនបានបើកហាងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំតាំងពីអំឡុងខែធ្នូ ឆ្នាំ២០២០ ដំបូងខ្លួនបើកតែភោជនីយដ្ឋាន និងផ្ទះសំណាក់ប៉ុណ្ណោះ។ ខ្លួនចាប់ផ្តើមបើកខាអ៉ារ៉ូខនៅក្នុងហាងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំកាលពីថ្ងៃមិនខាំ ខែវិច្ឆិកា ឆ្នាំ២០២២ ដោយមានបន្ទប់ខាអ៉ារ៉ូខចំនួន០២បន្ទប់។ ខ្លួនជាម្ចាស់ភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ដោយមុនពេលបើកហាង ខ្លួនបានធ្វើលិខិតស្នើសុំបើកហាងត្រឹមត្រូវ។ ដោយខ្លួនជាអ្នកមើលការខុសត្រូវ។ នៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំមានផ្តល់សេវាកម្មដូចជា បន្ទប់ខាអ៉ារ៉ូខ បន្ទប់ស្នាក់នៅ មានលក់មុខម្ហូបផ្សេងៗ និងមានលក់កេសជ្ជៈគ្រប់មុខផងដែរ។ ប៉ុន្តែចំពោះអ្វីផ្សេងទៀត មិនមាននោះទេ។ នៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំបុគ្គលិករួមមានមេការចំនួន០២នាក់ឈ្មោះ [redacted] សុខខួច ឈ្មោះ [redacted] គន្ធា និងបុគ្គលិកផ្សេងៗទៀតចំនួន០៧នាក់ ឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ជាវី ឈ្មោះ [redacted] ស្រីនិច ឈ្មោះ [redacted] លីហ្សា ឈ្មោះ [redacted] ណៃស៊ីម ឈ្មោះ [redacted] សេងអ័រ និងឈ្មោះ [redacted] ជាត មានតួនាទីជាអ្នករត់តុ អ្នកចាប់ទឹកកក អ្នកអង្គុយកំដរភ្ញៀវ អ្នកចាក់ស្រាជូនភ្ញៀវ អ្នកលាងចាន និងការងារផ្សេងៗនៅក្នុងហាង។ នៅពេលខ្លួនបើកខាអ៉ារ៉ូខនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ខ្លួនបានដាក់ពាក្យស្នើសុំទៅសាលាក្រុងច្បារមន ប៉ុន្តែខាងសាលាក្រុងប្រាប់ខ្លួនវិញថា ខ្លួនបើកបន្ទប់ខាអ៉ារ៉ូខតែពីរបន្ទប់ចឹង ចាំឆ្នាំក្រោយចាំធ្វើច្បាប់ស្នើបើកខាអ៉ារ៉ូខជាមួយច្បាប់អាជីវកម្មតែមួយទៅ។ ក្នុងមួយថ្ងៃៗ នៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំបានចំណូលចំនួន ១,០០០,០០០រៀល ហើយខ្លួនបានយកប្រាក់ទៅចំណាយផ្សេងៗនៅក្នុងហាងបើកប្រាក់ឲ្យបុគ្គលិក និងសល់ខ្លះខ្លួនយកទៅចិញ្ចឹមប្រពន្ធកូនផងដែរ។ ខ្លួនបានដាក់បម្រាមមិនឲ្យប្រព្រឹត្តអំពើសញ្ជ្ញាវកម្ម ការជួញដូរផ្លូវភេទ អំពើពេស្យាចារ ការកេងប្រវ័ញ្ចពលកម្មលើនារី និងកុមារផងដែរ និងបានដាក់បម្រាមហាមមិនឲ្យប្រើប្រាស់គ្រឿងញៀនទៀតផង។ តាំងពីខ្លួនបើកភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំមិនដែលសមត្ថកិច្ច ឬអាជ្ញាធរចុះទៅអប់រំណែនាំនោះទេ។ ចំពោះប្រពន្ធខ្លួនឈ្មោះ [redacted] គីមសួរ រាល់ថ្ងៃរស់នៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍ជាមួយខ្លួន និងនៅដើម្បីមើលថែកូនៗ នៅតូចតេប៉ុណ្ណោះ ដោយ

គាត់មិនដែលបានដឹងការងារក្នុងហាងនោះទេ។ បុគ្គលិកនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្ចាស់ពោធិ៍រំលេចធំ ខ្លួនជាអ្នកគិតប្រាក់ខែឲ្យបុគ្គលិក អ្នកដែលខ្លួនគិតប្រាក់ខែឲ្យមានឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ដាវី ឈ្មោះ [redacted] ស្រីនិច ឈ្មោះ [redacted] លីហ្សា ឈ្មោះ [redacted] ណៃស៊ីម ឈ្មោះ [redacted] សេងអ័រ និងឈ្មោះ [redacted] ជាត ទទួលបានប្រាក់ខែចំនួន១០០ដុល្លាអាមេរិក និងឈ្មោះ [redacted] សុខខួច និងឈ្មោះ [redacted] គន្ធា ទទួលបានប្រាក់ខែចំនួន១៥០ ដុល្លាអាមេរិក ក្នុងមួយខែ។ ខ្លួនមិនធ្លាប់មានទំនាស់ជាមួយឈ្មោះ [redacted] សុខខួច និងឈ្មោះ [redacted] ជាត ទេ មានតែខ្លួនទេតែងតែជួយឈ្មោះ [redacted] សុខខួច រាល់ទុក្ខលំបាក់របស់គាត់ និងសងបំណុលរបស់គាត់ថែមទៀតផង។ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥ និង៣៣នាទីរសៀល ពេលសមត្ថកិច្ចមកដល់បានឲ្យខ្លួនបិទហាងសិន បន្ទាប់មកសមត្ថកិច្ចបាននាំបុគ្គលិកខ្លួនទាំងអស់ទៅសាកសួរ បន្ទាប់មកខ្លួនក៏បានសួរទៅសមត្ថកិច្ចថា ហេតុអ្វីបានជានាំពួកគាត់ទៅចឹង សមត្ថកិច្ចបានប្រាប់វិញថា ដោយសារមានអ្នកជិតខាងប្តឹងថា ក្នុងហាងរបស់ខ្លួនមានអំពើសញ្ជារកម្ម។ ចំពោះរឿងនេះ ខ្លួនមិនបានផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ និងសញ្ជារកម្មនោះទេ ខ្លួនគ្រាន់តែបើកហាងលក់ដូរធម្មតាតែប៉ុណ្ណោះ ហើយចំពោះឈ្មោះ [redacted] សុខខួច បានធ្វើអ្វីនៅក្នុងហាងខ្លួននេះ ខ្លួនមិនបានដឹងទាំងអស់នោះទេ ព្រោះខ្លួនមិនសូវបាននៅក្នុងហាងជាប់រហូតនោះទេ ខ្លួនមានមុខរបរមួយផ្សេងដែលត្រូវមើលការខុសត្រូវដែរ។ ចំពោះការចោទប្រកាន់របស់ឈ្មោះ [redacted] សុខខួច មកលើខ្លួនមិនពិតនោះទេ ព្រោះខ្លួនមិនបានដឹងពីរឿងទាំងអស់នេះទេ។

- បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] គីមសួរ ឆ្លើយថា ខ្លួនមានមុខរបរបើកហាងភោជនីយដ្ឋាន និងផ្ទះសំណាក់យីហោម្ចាស់ពោធិ៍រំលេចធំ ដែលស្ថិតនៅក្នុងភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ នៅក្នុងហាងភោជនីយដ្ឋាន និងផ្ទះសំណាក់យីហោម្ចាស់ពោធិ៍រំលេចធំ មានកញ្ចុះចំនួនប្រហែល ១០ កញ្ចុះ បន្ទប់ផ្ទះសំណាក់ចំនួន០៦បន្ទប់ និងបន្ទប់ខាវ៉ាអូខេចំនួន០២បន្ទប់។ នៅក្នុងលិខិតអនុញ្ញាតអាជីវកម្មភោជនីយដ្ឋាន និងផ្ទះសំណាក់យីហោម្ចាស់ពោធិ៍រំលេចធំ គឺឈ្មោះ [redacted] សុងហាក់ ជាម្ចាស់ ចំណែកខ្លួនជាប្រពន្ធរបស់គាត់។ បច្ចុប្បន្នខ្លួន ឈ្មោះ [redacted] សុងហាក់ ឈ្មោះ [redacted] គីមអេង អាយុ ១៦ឆ្នាំ ឈ្មោះ [redacted] គីមអ៊ីក អាយុ ១៦ឆ្នាំ ឈ្មោះ [redacted] សៃហ្គិច អាយុប្រហែល ៧៨ឆ្នាំ មានបុគ្គលិកឈ្មោះ សែន ភេទប្រុស ឈ្មោះ តាន ភេទស្រី (ចុងភៅ) ឈ្មោះ [redacted] លីហ្សា ភេទស្រី អាយុ ១៨ឆ្នាំ ឈ្មោះ [redacted] ណៃស៊ីម ហៅ អាស៊ីម ភេទ ស្រី អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] ជាត អាយុ ៣១ឆ្នាំ ភេទស្រី (អ្នកលាងចាន) កំពុងរស់នៅ ក្នុងទីតាំងភោជនីយដ្ឋាន និងផ្ទះសំណាក់យីហោម្ចាស់ពោធិ៍រំលេចធំ។ បុគ្គលិកដែលកំពុងបម្រើការងារនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់យីហោម្ចាស់ពោធិ៍រំលេចធំ រួមមាន៖ មេការចំនួន០២នាក់ ឈ្មោះ [redacted] សុខខួច និងឈ្មោះ [redacted] គន្ធា និងបុគ្គលិកផ្សេងៗមានចំនួន០៦នាក់ ឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ដាវី ឈ្មោះ [redacted] ស្រីនិច ឈ្មោះ [redacted] លីហ្សា ឈ្មោះ [redacted] ណៃស៊ីម ឈ្មោះ [redacted] សេងអ័រ ឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ដាវី ឈ្មោះ [redacted] ស្រីនិច ឈ្មោះ [redacted] លីហ្សា ឈ្មោះ [redacted] ណៃស៊ីម ឈ្មោះ [redacted] សេងអ័រ មានតួនាទីជាអ្នករត់តុ ចាប់ទឹកកក អង្គុយកំដរភ្ញៀវ កាន់កញ្ចុះ នារីចាក់ស្រាជូនភ្ញៀវ បន្ទប់ខាវ៉ាអូខេ និងឈ្មោះ [redacted] ជាត។ ខ្លួនបានចាប់ផ្តើមអាជីវកម្មតាំងពីអំឡុងខែធ្នូ ឆ្នាំ២០២០ ដោយដំបូងបើកតែភោជនីយដ្ឋាន និងផ្ទះ សំណាក់យីហោម្ចាស់ពោធិ៍ រំលេចធំ តែប៉ុណ្ណោះ។ កន្លងមកខ្លួនបើកតែអាជីវកម្មហាងភោជនីយដ្ឋាន និងផ្ទះសំណាក់យីហោម្ចាស់ពោធិ៍រំលេចធំ លុះអំឡុងឆ្នាំ២០២២ ខ្លួនបើកសាកល្បងអាជីវកម្មខាវ៉ាអូខេចំនួន០២បន្ទប់ទៀត ដោយសារអាជីវកម្មភោជនីយដ្ឋាន និងផ្ទះសំណាក់គ្មានភ្ញៀវ និងដោយគ្មានប្រាក់គ្រប់គ្រាន់ក្នុងការបើកខាវ៉ាអូខេទាំងស្រុង។ ខ្លួន ចាប់ផ្តើមអាជីវកម្មបើកខាវ៉ាអូខេនៅក្នុងហាងភោជនីយដ្ឋាន និងផ្ទះសំណាក់យីហោម្ចាស់ពោធិ៍រំលេចធំ ក្នុងរឿងសុំការអនុញ្ញាត

បើកខាភ៉ាអូខេ គឺខ្លួនមិនដឹងទេ ព្រោះអាជីវកម្មខាងលើជាការគ្រប់គ្រងដោយ ថ្នាល់របស់ប្តីខ្លួនឈ្មោះ [redacted] សុង ហាក់។ នៅក្នុងហាងភោជនីយដ្ឋាន ផ្ទះសំណាក់ និងខាភ៉ាអូខេយីហោម្លប់ពោធិ៍រលេចធំ ខ្លួនមានតួនាទីជាអ្នកគិត លុយម្ហូបនៅពេលប្តីមិននៅ ខ្លួនចាំតែមើលកូន បោកខោអាវចុងភៅ និងជួយមើលការខុសត្រូវក្នុងហាង ប៉ុណ្ណោះ។ ខ្លួនមិនធ្លាប់បានអនុញ្ញាតឲ្យបុគ្គលិកនៅក្នុងហាងបំពើសេវាកម្មផ្លូវភេទនោះទេ។ ចំពោះករណីពួកគាត់ឆ្លើយថាធ្លាប់ចេញក្រៅជាមួយភ្ញៀវ គឺខ្លួនពីមុនមកមិនដែលដឹងទេ លុះមកដល់ទល់សមត្ថកិច្ចចូល មកធ្វើការឆែកឆេរ និងសាកសួរ ទើបខ្លួនដឹងថាបុគ្គលិកធ្លាប់ចេញក្រៅដើម្បីស្វែងរកប្រាក់បន្ថែម។ ខ្លួនសូមបញ្ជាក់ថា ខ្លួនមិនដឹងទេ ព្រោះប្តីខ្លួនជាអ្នកគ្រប់គ្រង ដោយឡែកខ្លួនដឹងតែធ្វើម្ហូប និងមើលថែកូនតែប៉ុណ្ណោះ។ ចំពោះការដាក់នារីឲ្យភ្ញៀវខ្លួនមិនដឹងទេ។ ខ្លួនមិនធ្លាប់បានដាក់បំរាមហាមឃាត់ទៅបុគ្គលិក នារីទាំងអស់ នោះទេ។ ខ្លួនមិនដឹងថានារីទាំងអស់នោះមានគំនិតចង់ប្រព្រឹត្តអំពើអស់នេះដែរ។ ចាប់តាំងពីបើកភោជនីយដ្ឋានផ្ទះសំណាក់ និងខាភ៉ាអូខេយីហោម្លប់ពោធិ៍រលេចធំនេះមក ធ្លាប់ត្រូវបានសមត្ថកិច្ចចុះទៅអប់រំ ណែនាំ ម្តងម្កាលដែរ ហើយក៏ធ្លាប់បានធ្វើកិច្ចសន្យាចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ រួចហើយ ជាមួយសមត្ថកិច្ច ដែលមានខ្លឹមសារដូចតទៅ៖

-ចំពោះផ្ទះសំណាក់ មិនទទួលភ្ញៀវដែលមានអាយុក្រោម១៨ឆ្នាំ (ទាំងប្រុសទាំងស្រី) លើកលែង មកជាមួយឪពុកម្តាយ ឬអាណាព្យាបាល។

-មិនប្រព្រឹត្តអំពើសញ្ជាវកម្ម ការជួញដូរផ្លូវភេទ អំពើពេស្យាចារ ការកេងប្រវ័ញ្ចពលកម្មលើនារី និងកុមារ

-ធានាមិនប្រព្រឹត្តអំពើណាដែលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈសង្គម ទំនៀមទំនាប់ ប្រពៃណីជាតិ សេចក្តីថ្លៃថ្នូរ និងសុខមាលភាពសង្គម។ ក្នុងករណីមិនគោរពកិច្ចសន្យានេះ សូមទទួលទោសចំពោះមុខច្បាប់។

កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥ និង៣៣នាទីរសៀល ខ្លួន និងប្តីឈ្មោះ[redacted] សុង ហាក់ បានឃើញសមត្ថកិច្ចធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **សុខខួច** និងឈ្មោះ [redacted] **ជាត** នៅក្នុងហាងភោជនីយដ្ឋាន ផ្ទះសំណាក់ និងខាភ៉ាអូខេយីហោម្លប់ពោធិ៍រលេចធំដែរ។ ខ្លួនមិនដឹងអំពីមូលហេតុដែលសមត្ថកិច្ចមិនឃាត់ខ្លួនរូបខ្លួន និងប្តីមកដែរ ប៉ុន្តែថ្ងៃកើតហេតុសមត្ថកិច្ចក៏បាននាំប្តីខ្លួន ទៅសាកសួរនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺដែរ ហើយខ្លួនក៏មិនដឹងថាសមត្ថកិច្ចសួរអំពីអ្វីទេ ហើយក៏មិនដឹងថាប្តីខ្លួនបានឲ្យលុយ ឬអ្វីទៅគេនោះទេ ព្រោះខ្លួនមិនបានសួរនាំប្តី។ លុះរហូតដល់ម៉ោងប្រហែល៦ល្ងាច ទើបគេអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ។ ខ្លួនពុំធ្លាប់មានគំនុំជាមួយឈ្មោះ [redacted] **សុខខួច** ទេ។ ខ្លួនតែងតែជួយរាល់ទុក្ខធុរៈ មិនថាការជួយដោះបំណុលរបស់គាត់ថែមទៀតផង។ បុគ្គលិកនៅក្នុងហាង ដែលទទួលបានប្រាក់ខែរួមមាន ឈ្មោះ[redacted] **លីហ្សា** ចំនួន១០០$ និងម្តាយឈ្មោះ លីហ្សា ចំនួន ៧០០,០០០រៀល មេការឈ្មោះ [redacted]**សុខខួច** ចំនួន ១៥០$, ឈ្មោះ [redacted] ស្រីនិច ចំនួន ៥០០,០០០រៀល ឈ្មោះ [redacted] សេងអ័រ ចំនួន ៥០០,០០០រៀល។ ចាប់តាំងពីដឹងថា មានដីកាបង្គាប់ឲ្យចូលពីតុលាការមកឈ្មោះ [redacted] សុងហាក់ បច្ចុប្បន្នបានទៅស្នាក់នៅខេត្តតាកែវ។ ដោយសារតែតាំងពីដឹងថាមានដីកាបង្គាប់ឲ្យចូលរបស់តុលាការមក គាត់ពិបាកចិត្ត ម្យ៉ាងហាងភោជនីយដ្ឋាន ផ្ទះសំណាក់ និងខាភ៉ាអូខេម្លប់ពោធិ៍រលេចធំបានបិទមិនបានដំណើរការរពាលេញអត់មានភ្ញៀវ ហើយគាត់ទៅដើរលេង និងលំហែនៅផ្ទះបងប្អូនតែម្តង។ ខ្លួនមិនបានដឹងទេដោយឡែកបញ្ហាហាងភោជនីយដ្ឋាន ផ្ទះសំណាក់ និងខាភ៉ាអូខេម្លប់ពោធិ៍រលេចធំគាត់ទុកឲ្យខ្លួន និងឪពុកឈ្មោះ[redacted] **គីមឡុង** ជាអ្នកដោះស្រាយ។

- បានឃើញចម្លើយរបស់សាក្សីឈ្មោះ[redacted] ស្រីនិច ឆ្លើយថា កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ ខ្លួនមកបម្រើការងារនៅហាងអាហារដ្ឋានយីហោម្លប់ពោធិ៍រលេចធំ បានមកធ្វើការនៅហាងនេះជាមួយបងស្រីម្នាក់

ដែលធ្លាប់ស្គាល់គ្នាឈ្មោះ [redacted] ស្រីនាង គាត់មានមុខងារជាអ្នកចាក់ចម្រៀងឲ្យភ្ញៀវ ហើយរូបខ្លួនមិនដែលធ្លាប់ចេញទៅក្រៅជាមួយភ្ញៀវទេ និងទទួលបានប្រាក់ខែពីហាងនេះបានចំនួន ៥០០,០០០រៀល ក្នុងមួយខែ ហើយលុយធីបប្រចាំថ្ងៃបានប្រហែលចំនួន ៥០,០០០រៀល ទៅ១០០,០០០រៀល ហើយនៅក្នុងហាងនោះមានថៅកែចំនួន០២នាក់ ជាប្តីប្រពន្ធនឹងគ្នា មានមេការចំនួន០២នាក់ ឈ្មោះ ស្រីខួច និងឈ្មោះ ម៉ាប់។ ខ្លួនធ្វើការនៅទីនេះបានស្គាល់ឈ្មោះ [redacted] សេងអ៊ី, បងណា, ស្រីឌីន, និងបងស្រីឈ្មោះ សែន ហើយអ្នកទាំងអស់នោះជាអ្នកបម្រើការនៅក្នុងហាងនោះ។ ពេលដែលភ្ញៀវត្រូវការខ្លួន ខ្លួនតែងតែប្រាប់មេការជាមុនសិន ហើយតម្លៃខ្លួនរបស់ខ្លួនជាអ្នកសុំដោយខ្លួនឯង ដោយម្តងពីតម្លៃ ១៥០ ទៅ ២០០ ដុល្លាអាមេរិក ហើយពេលដែលចរចារត្រូវគ្នាជាមួយភ្ញៀវគឺខ្លួនទៅសុំមេការឈ្មោះ ខួច ជាមុនសិនឲ្យបើកផ្ទះសំណាក់ នៅក្នុងហាងនោះតែម្តង។ ហើយលុយដែលបានពីការរួមភេទគឺយកទៅឲ្យមេការឈ្មោះ ខួច សិន។ ហើយពេលដែលខ្លួនរួមភេទគឺត្រូវបង់ឲ្យមេការចំនួន ១០ដុល្លាអាមេរិក ហើយភ្ញៀវជាអ្នកចេញថ្លៃបន្ទប់ក្នុងផ្ទះសំណាក់ និងថ្លៃស្រោមអនាម័យ។ ប្រាក់សេវាកម្មផ្លូវភេទដែលទទួលបាន ខ្លួនយកទៅចាយវាយប្រចាំថ្ងៃ និងផ្ញើរទៅឪពុកម្តាយ។ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥ និង៣០នាទី ស្ថិតនៅក្នុងហាងអាហារដ្ឋាន និងផ្ទះសំណាក់យីហោម្លប់ពោធិ៍រលេចធំ ខ្លួន ថៅកែស្រី ថៅកែប្រុស មេការស្រីឈ្មោះ ខួច ឈ្មោះ ឌីន ឈ្មោះ អាហ្សា ឈ្មោះ ស៊ីម ឈ្មោះ អ័រ និងឈ្មោះ ណា កំពុងធ្វើការក្នុងហាង ស្រាប់តែសមត្ថកិច្ចបានចុះមកឃាត់ខ្លួន ឈ្មោះ [redacted] សុខខួច ត្រូវជាមការ និងឈ្មោះ [redacted] ជាត ត្រូវជាអ្នកលាងចាន និងកសាងសំណុំរឿងបញ្ជូនមកអយ្យការតែម្តង។

- បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] លីហ្សា ឆ្លើយថា កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០២១ ខ្លួនមកបម្រើការងារនៅហាងអាហារដ្ឋានយីហោម្លប់ពោធិ៍រលេចធំ ជាមួយម្តាយរបស់ខ្លួនឈ្មោះ [redacted] សៀន ហើយនៅក្នុងហាងនោះមានកញ្ចុះស៊ីធីកប្រហែល២០កញ្ចុះ បន្ទប់ចំនួន០៦បន្ទប់ (ពីមុនថៅ កែហាងបើក បន្ទប់ ផ្ទះសំណាក់សម្រាប់ឲ្យភ្ញៀវរួមភេទ ប៉ុន្តែឥឡូវបិទផ្ទះសំណាក់) និងបន្ទប់ខារ៉ាអូខេចំនួន០២បន្ទប់។ ខ្លួន មាន តួនាទីជាអ្នករត់តុតាមកញ្ចុះ ទទួលប្រាក់ខែពីថៅកែចំនួន ១០០ដុល្លាអាមេរិក ក្នុងមួយខែ ចំណែកម្តាយរ បស់ ខ្លួនធ្វើជាចុងភៅចំនួន ៧០០,០០០រៀល ក្នុងមួយខែ។ នៅក្នុងហាងមិននារីកំដរភ្ញៀវស៊ីប្រាក់ខែទេ (ស៊ីតែលុយធីប) គឺមានអ្នករត់តុចំនួន ០២នាក់ ឈ្មោះ [redacted] លីហ្សា និងឈ្មោះ ណៃស៊ីម និងមេការចំនួន០២នាក់ ឈ្មោះ ម៉ាប់ និងឈ្មោះ ខួច ។ នៅពេលភ្ញៀវធីកស៊ីត្រូវការនារីមេការឈ្មោះ[redacted] ឬឈ្មោះ ខួច ជាអ្នកទូរស័ព្ទ ទៅ នារី ខាងក្រៅមកកំដរភ្ញៀវ ចំណែកខ្លួនជាអ្នកចាំមើលភ្ញៀវថា ភ្ញៀវត្រូវការកម្មង់អ្វីបន្ថែម ប៉ុន្តែបើភ្ញៀវឲ្យខ្លួននៅអង្គុយកំដរគឺខ្លួននៅកំដរមួយភ្លែត។ នៅពេលភ្ញៀវត្រូវការនារីរួមភេទជាមួយ ត្រូវទាក់ទងជាមួយមេការឈ្មោះ ម៉ាប់ ឬឈ្មោះ ខួច សិនថា "តើនារីអាចរួមភេទជាមួយគាត់បានឬអត់?" ហើយក្នុងតម្លៃខ្លួនប៉ុន្មាន? នៅពេល និយាយត្រូវតម្លៃគ្នាជាមួយមេការ។ ខ្លួនមិនបានដឹងពីតម្លៃនារីខាងក្រៅទេ ព្រោះគេនិយាយគ្នាតែតាមទូរស័ព្ទ។ ខ្លួនធ្លាប់ផ្តល់សេវាកម្មផ្លូវភេទបានចំនួន០២លើក នៅផ្ទះសំណាក់ខាងក្រៅបានតម្លៃពី១០០ទៅ២០០ដុល្លាអាមេរិក។ ខ្លួនបានយកប្រាក់សេវាកម្មផ្លូវភេទដែលបានទទួលពីភ្ញៀវយកទៅចាយវាយប្រចាំថ្ងៃ។ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥ និង៣០នាទី ស្ថិតនៅក្នុងហាងអាហារដ្ឋាន និងផ្ទះសំណាក់យីហោម្លប់ពោធិ៍រលេចធំ ខ្លួន ថៅកែស្រី ថៅកែប្រុស មេការស្រីឈ្មោះ ខួច ឈ្មោះ ឌីន ឈ្មោះ ស្រីនិច ឈ្មោះ ស៊ីម ឈ្មោះ អ័រ និងឈ្មោះ ណា កំពុងធ្វើការក្នុងហាង ស្រាប់តែសមត្ថកិច្ចបានចុះមកឃាត់ខ្លួន ឈ្មោះ[redacted] សុខខួច ត្រូវជាមការ និងឈ្មោះ [redacted] ជាត ត្រូវជាអ្នកលាងចាន និងកសាងសំណុំរឿងបញ្ជូនមកអយ្យការតែម្តង។

- បានឃើញចម្លើយរបស់សាក្សីឈ្មោះ[redacted] ជាវី ហៅ អាម៉ី ឆ្លើយថា ខ្លួនបានបម្រើការងារនៅហាង

អាហារដ្ឋាន ផ្ទះសំណាក់ម្លប់ពោធិ៍រលេចធំ កាលពីថ្ងៃមិនចាំ ខែសីហា ឆ្នាំ២០២២ មានតួនាទីជាអ្នកកាន់កញ្ចុះ បានប្រាក់ខែចំនួន ៥០០,០០០រៀល ក្នុងមួយខែ ខ្លួនមកធ្វើការតាមរយៈមេការឈ្មោះ **ខួច** ប៉ុន្តែខ្លួនមិនបានប្រាក់ខែទេ គឺគ្រាន់តែជានារីស៊ីម៉ោង និងលុយធីបពីភ្ញៀវប៉ុណ្ណោះ ដោយបានស្គាល់ថៅកែស្រីឈ្មោះ **លីម ឆ័ត សួរ** ថៅកែប្រុសឈ្មោះ [redacted] **សុងហាក់** និងមេការស្រីឈ្មោះ **ខួច** ហើយបានស្គាល់នារីក្នុងហាងឈ្មោះ **ដីន ឈ្មោះ ស៊ីម ឈ្មោះ អាហ្សា ឈ្មោះ អាអ៊ី ឈ្មោះ និច្ច** និង**ចៃឈ្មោះ ណា** ពួកគាត់ជានារីបម្រើការងារនៅក្នុងហាងទាំងអស់។ ខ្លួនបានដឹងថាបន្ទាប់ពីភ្ញៀវផឹកស៊ីមានអារម្មណ៍ចង់រួមភេទ គឺភ្ញៀវទៅសួរនាំមេការទាំងពីរឈ្មោះ ខួច និងឈ្មោះ **ម៉ាប់** ដោយខ្លួនឯង បើភ្ញៀវពេញចិត្តនារីម្នាក់ណា គឺមេការជាអ្នកទូរស័ព្ទឬនិយាយសួរនាំថាអាចចូលជាមួយភ្ញៀវបានអត់? មេការទាំងពីរមិនដែលបង្ខំនារីឲ្យទៅរួមភេទជាមួយភ្ញៀវទេ។ កាលពីអំឡុងថ្ងៃមិនចាំ ខែកក្កដា ឆ្នាំ២០២២ ពេលខ្លួននៅកំពង់ស្ពឺដំបូងដោយខ្លួនត្រូវការលុយធ្វើឲ្យប្អូន ខ្លួនបានប្រាប់មេការឈ្មោះ ខួច ជួយរកភ្ញៀវឲ្យក្នុងតម្លៃ ១០០ ដុល្លាអាមេរិក។ ពេលនោះមេការប្រាប់ខ្លួនថា មានភ្ញៀវតែត្រូវរងចាំ៣ទៅ៤ថ្ងៃសិនបន្ទាប់ពីមេការរកភ្ញៀវបានហើយ គឺភ្ញៀវជាអ្នកមកយកខ្លួនចេញទៅគេងនៅផ្ទះសំណាក់ខាងក្រៅ ពេលរួមភេទជាមួយភ្ញៀវរួច ភ្ញៀវបានឲ្យលុយមកខ្លួនចំនួន១០០ដុល្លាអាមេរិក ហើយខ្លួនបានឲ្យលុយចំនួន ១០ដុល្លាអាមេរិកទៅមេការឈ្មោះ **ខួច** ប៉ុន្តែគាត់មិនបានយកទេ ព្រោះគាត់ថាកំពុងខ្វះលុយ ហើយក្រោយៗមកទៀត ខ្លួនបានប្រាប់គាត់ថា បើមានភ្ញៀវផឹកស៊ីតាមកញ្ចុះឲ្យគាត់ប្រាប់ខ្លួនផង ខ្លួនទៅបម្រើចាក់ស្រាឲ្យភ្ញៀវ ព្រោះខ្លួនចង់បានលុយធីប។ ប្រាក់សេវាកម្មផ្លូវភេទដែលខ្លួនទទួលបាន ខ្លួនយកទៅចាយវាយប្រចាំថ្ងៃ និងសម្រាប់ទុកចាយវាយពេលក្រោយ។ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥ និង៣០នាទី ស្ថិតនៅក្នុងហាងអាហារដ្ឋាន និងផ្ទះសំណាក់យីហោម្លប់ពោធិ៍រលេចធំ ខ្លួន ថៅកែស្រី ថៅកែប្រុស មេការស្រីឈ្មោះ **ខួច ឈ្មោះ ឌីន ឈ្មោះ ស្រីនិច ឈ្មោះ ដាវ ឈ្មោះ ស៊ីម ឈ្មោះ អ័រ** និង**ឈ្មោះ ណា** កំពុងធ្វើការក្នុងហាង ស្រាប់តែសមត្ថកិច្ចបានចុះមកឃាត់ខ្លួន ឈ្មោះ [redacted] **សុខខួច** ត្រូវជាមការ និងឈ្មោះ [redacted] **ជាត** ត្រូវជាអ្នកលាងចាន និងកសាងសំណុំរឿងបញ្ជូនមកអយ្យការតែម្តង។

- បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] **ចាន់ឌីន** ហៅ **ស្រីម៉ៅ** ឆ្លើយថា ខ្លួនបានបម្រើការងារនៅអំឡុងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ តាមរយៈមេការឈ្មោះ **ខួច** ក្នុងហាងអាហារដ្ឋាន ផ្ទះសំណាក់ម្លប់ពោធិ៍រលេចធំ ដែលមានថៅកែស្រីឈ្មោះ **គីមសួរ**។ ពេលទៅដល់ដំបូងខ្លួនមានតួនាទីជាអ្នកបម្រើសេវាទូទៅជូនភ្ញៀវតាមកញ្ចុះដែលបានប្រាក់ខែចំនួន ១០០ ដុល្លាអាមេរិក ក្នុងមួយខែ ធ្វើនៅទីនោះបានរយៈពេលពីរខែ ខ្លួនបានទទួលការងារបន្ថែមគឺត្រូវអង្គុយកំដរភ្ញៀវផឹកស៊ីតាមកញ្ចុះ និងក្នុងបន្ទប់ខារ៉ាអូខេ។ ខ្លួនចាប់ផ្តើមគេងជាមួយភ្ញៀវក្នុងខែតុលា បានប្រហែល០២លើក។ ពេលដែលភ្ញៀវចង់រួមភេទជាមួយខ្លួន គឺភ្ញៀវត្រូវទៅសួរតម្លៃខ្លួនរូបខ្លួនពីមេការឈ្មោះ **ខួច** តម្លៃខ្លួនរូបខ្លួន គឺ២០០ដុល្លាអាមេរិក ក្នុងមួយដង មេការអ្នកប្រាប់តម្លៃនេះទៅឲ្យភ្ញៀវដែលត្រូវការខ្លួន។ ពេលត្រូវតម្លៃគ្នាហើយ គឺភ្ញៀវត្រូវឲ្យប្រាក់គ្រប់ចំនួនទៅមេការ។ ពេលទទួលលុយពីភ្ញៀវបាន មេការយកលុយទាំងអស់ទុកសិន។ ពេលខ្លួនរួមភេទជាមួយភ្ញៀវហើយ ទើបមេការប្រគល់លុយ ២០០ដុល្លាអាមេរិកមកឲ្យខ្លួន ពេលនោះខ្លួនត្រូវដក ១០ដុល្លាអាមេរិក ឲ្យទៅមេការ ព្រោះខ្លួនឃើញអ្នកធ្វើការនៅទីនោះមុនៗ គេឲ្យប៉ុណ្ណឹងដែរ។ ខ្លួនធ្លាប់រួមភេទជាមួយភ្ញៀវនៅក្នុងផ្ទះសំណាក់ក្នុងហាងចំនួន២ដង ដោយម្តងពេលនោះភ្ញៀវបានឲ្យលុយថ្លៃបន្ទប់ទៅមេការចំនួន៣០,០០០រៀល ក្រោយពេលរួមភេទរួច។ ប្រាក់សេវាកម្មផ្លូវភេទដែលទទួលបានខ្លួនយកទៅចាយវាយប្រចាំថ្ងៃ និងសម្រាប់ទុកចាយវាយពេលក្រោយ។ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥ និង៣០នាទី ស្ថិតនៅក្នុងហាងអាហារដ្ឋាន និងផ្ទះសំណាក់យីហោម្លប់ពោធិ៍រលេចធំ ខ្លួន ថៅកែ



Scanned with CamScanner

ស្រី ថៅកែប្រុស មេការស្រីឈ្មោះ ខួច ឈ្មោះ ស្រីនិច ឈ្មោះ ដាវី ឈ្មោះ ស៊ីម ឈ្មោះ អ័រ និងឈ្មោះ ណ[illegible] ធ្វើការក្នុងហាង ស្រាប់តែសមត្ថកិច្ចបានចុះមកឃាត់ខ្លួន ឈ្មោះ លួន សុខខួច ត្រូវជាមការ និងឈ្មោះ [illegible] ត្រូវជាអ្នកលាងចាន និងកសាងសំណុំរឿងបញ្ជូនមកអយ្យការតែម្តង។

- បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted]សេងអ័រ ឆ្លើយថា កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០២២ [illegible] ការងារនៅហាងអាហារដ្ឋានយីហោម្លប់ពោធិ៍រលេចធំ ជាមួយមិត្តភក្តិម្នាក់ឈ្មោះ [redacted] ស្រីនិច រស់នៅ[illegible] ស្រុកចំការលើ ខេត្តកំពង់ចាម។ ខ្លួនបំរើការងារនៅទីនេះដោយមានមុខងារជាអ្នករត់តុមិនទទួលបាន[illegible] នោះទេ គឺទទួលបានលុយធីបពីភ្ញៀវបានចំនួន ៤០,០០០រៀល ទៅ ៥០,០០០រៀល អាស្រ័យលើភ្ញៀវ[illegible] កន្លងមកមេការឈ្មោះ ខួច ធ្លាប់ណែនាំខ្លួនឲ្យទៅរួមភេទជាមួយភ្ញៀវ ប៉ុន្តែខ្លួនមិនព្រមទៅទេ។ ខ្លួនត្រូវចំណូល សេវាកម្មផ្លូវភេទដែលបានទទួលពីភ្ញៀវយកទៅចាយវាយប្រចាំថ្ងៃ។ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលា ម៉ោង១៥ និង៣០នាទី ស្ថិតនៅក្នុងហាងអាហារដ្ឋាន និងផ្ទះសំណាក់ យីហោម្លប់ពោធិ៍រលេចធំ ខ្លួន ថៅកែស្រី ថៅកែប្រុស មេការស្រីឈ្មោះ ខួច ឈ្មោះ ស្រីនិច ឈ្មោះ ដាវី ឈ្មោះ ស៊ីម ឈ្មោះ ឌីន និងឈ្មោះ [redacted] កំពុងធ្វើ ការក្នុងហាង ស្រាប់តែសមត្ថកិច្ចបានចុះមកឃាត់ខ្លួន ឈ្មោះ [redacted] សុខខួច ត្រូវជាមការ និងឈ្មោះ [redacted] ជាត ត្រូវជាអ្នកលាងចាន និងកសាងសំណុំរឿងបញ្ជូនមកអយ្យការតែម្តង។

- បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] ណៃស៊ីម ហៅ អាស៊ីម ឆ្លើយថា ខ្លួនបានមកចំរើ[illegible] តាមរយៈអ្នកជិតខាងឈ្មោះ លី (បច្ចុប្បន្នគាត់បានឈប់ធ្វើការហើយ) ខ្លួនបានមកធ្វើការនៅហាងមុខងារ[illegible] រត់តុបានប្រាក់ខែ ១០០(មួយរយ)ដុល្លាអាមេរិក និងបានស្គាល់ថៅកែស្រីឈ្មោះ [redacted] គីមសួ ថៅកែប្រុសឈ្មោះ សេង សុខហាក់ និងមេការស្រីឈ្មោះ ខួច ០១នាក់ ហើយបានស្គាល់នារីក្នុងហាងឈ្មោះ ឌីន ណៃ ឈ្មោះ តុំ ឈ្មោះ អាហ្សា ឈ្មោះ អ័រ ឈ្មោះ និច្ច និងចៃឈ្មោះ ណា ពួកគាត់ជានារីបម្រើក្នុងអំឡុងឆ្នាំ២០២០ ពេលដែលខ្លួនបាន[illegible] ការងារជាអ្នករត់តុ ខ្លួនបានឃើញភ្ញៀវនិយាយជាមួយមេការឈ្មោះ ខួច ដើម្បីរកនារីខាងក្រៅឲ្យភ្ញៀវរួមភេទ[illegible] មួយក្នុងតម្លៃ៥០ដុល្លាអាមរិក ទៅ១០០ដុល្លាអាមេរិក។ បន្ទាប់ពីនារីរួមភេទជាមួយភ្ញៀវរួច គឺត្រូវឲ្យលុយទៅ មេការឈ្មោះ ខួច ចំនួន ៥០,០០០រៀល ថ្លៃរកភ្ញៀវឲ្យ ហើយភ្ញៀវក៏បានឲ្យទៅមេការចំនួន ៥០,០០០រៀល ចំណែកថ្លៃបន្ទប់ និងស្រោមអនាម័យចំនួន ៣០,០០០រៀល ឲ្យមេការជាអ្នកប្រគល់ឲ្យទៅថៅកែ។ ចំពោះ[illegible] ថ្លៃរួមភេទភ្ញៀវឲ្យទៅមេការជាអ្នកទុក ពេលខ្លះភ្ញៀវយកលុយ ឲ្យទៅនារីផ្ទាល់ ឬ ភ្ញៀវខ្លះទៀតក៏[illegible] តាម ABA របស់ថៅកែ ប៉ុន្តែថៅកែមិនដឹងលុយថ្លៃអ្វីទេ។ ពេលនារីរួមភេទរួច មេការដកលុយនោះចំនួន ៤០,០០០រៀល និងពេលខ្លះទៀតភ្ញៀវឲ្យគិតលុយក្នុងបុងជាមួយផ្សេងៗ។ លុះដល់ខែកញ្ញា ឆ្នាំ២០២២ ថៅកែបាន សម្រេចចិត្តចេញទៅរួមភេទជាមួយភ្ញៀវបានចំនួន ០១ដង ក្នុងតម្លៃ ៣០០,០០០រៀល ដោយមិនបានគ្រាប់[illegible] ថៅកែ ឬមេការទាំងពីរទេ។ នៅក្នុងហាងខ្លួនធ្លាប់ដឹងថា មីងឈ្មោះ ជាត (ម៉ែ ជាត) ធ្លាប់ទទួលភ្ញៀវរួមភេទនៅ ក្នុងហាង (ផ្ទះសំណាក់) ពេលខ្លះមានភ្ញៀវទាក់ទងចង់បាននារីទៅរួមភេទតាមរយៈគាត់ ប៉ុន្តែខ្លួនមិនដឹងគាត់ ឆ្លើយថាម៉េចទេ។ ប្រាក់សេវាកម្មផ្លូវភេទ ដែលខ្លួនទទួលបាន ខ្លួនយកទៅចាយវាយប្រចាំថ្ងៃ និងសម្រាប់ទុក ចាយវាយពេលក្រោយ។ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៥-៣០នាទី ស្ថិតនៅក្នុងហាង អាហារដ្ឋាន និងផ្ទះសំណាក់ យីហោម្លប់ពោធិ៍រលេចធំ ខ្លួន ថៅកែស្រី ថៅកែប្រុស មេការស្រីឈ្មោះ ខួច ឈ្មោះ ស្រីនិច ឈ្មោះ ដាវី ឈ្មោះ អ័រ ឈ្មោះ ឌីន និងឈ្មោះ ណា កំពុងធ្វើការក្នុងហាង ស្រាប់តែសមត្ថកិច្ចបានចុះមក ឃាត់ខ្លួន ឈ្មោះ [redacted] សុខខួច ត្រូវជាមេការ និងឈ្មោះ [redacted] ជាត ត្រូវជាអ្នកលាងចាន និងកសាងសំណុំរឿង បញ្ជូនមកអយ្យការតែម្តង។

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថា ៖ ឈ្មោះ ស្រីខួច បានឆ្លើយបដិសេធ និងថាមិនបា[illegible]
អស់។ ប៉ុន្តែនៅក្នុងដំណាក់កាលនគរបាលយុត្តិធម៌ ឈ្មោះនេះបានឆ្លើយផ្ទុយ។ ប៉ុន្តែចម្លើយរបស់[illegible]
បានឆ្លើយជូនតុលាការអស់ហើយ។ ចំពោះនៅទីតាំងកើតហេតុ គឺមានគ្រប់ទាំងអស់តាំងពីភោជនីយដ្ឋាន[illegible]
អូខេ និងផ្ទះសំណាក់។ មានធាតុផ្សំគ្រប់គ្រាន់ ដូច្នេះខ្ញុំបាទស្នើសុំឲ្យតុលាការពិនិត្យ និងសម្រេច[illegible]
ចំណែកសំណងគឺមិនទាមទារទាំងអស់ ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីការពិភាក្សាដេញដោលនាពេលសវនាការ[illegible]
មកឃើញថា ជនជាប់ចោទបានបដិសេធចំពោះការចោទប្រកាន់របស់តំណាងអយ្យការ ប៉ុន្តែជន[illegible]
ភស្តុតាងណាមួយដែលអាចដោះបន្ទុកបាននោះទេ ពីព្រោះសាក្សីដែលមានវត្តមាននៅក្នុងសវនាការ[illegible]
ឯកសារនានានៅក្នុងសំណុំរឿងដែលជាភស្តុតាងបានបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទពិតជាបាន[illegible]
ការចោទប្រកាន់របស់តំណាងអយ្យការ ច្រាកដមែន។ បើទោះបីជាឈ្មោះ [redacted] ដាវី បានអះអាងថា [illegible]
ស្រីខួច មិនបានយកប្រាក់ពីខ្លួន តែអំពើនេះស្តែងចេញពីដំបូងមកម្ល៉េះតាមរយៈការណែនាំ។ ចំពោះ[illegible]
ក៏ដូច្នេះដែរ មានចម្លើយនៅដំណាក់កាលមន្ត្រីយុត្តិធម៌ និងនៅដំណាក់កាលចៅក្រមស៊ើបសួរជាភស្តុតាង។
ឈ្មោះ [redacted] គង្គា ក៏បានប្រព្រឹត្តដូចគ្នានោះដែរ។ ចំពោះម្ចាស់ហាងក៏មានអំពើដែលដូចដែលបានចោទប្រកាន់
នោះដែរ តាមរយៈចម្លើយកំណត់ហេតុ ដែលផ្តល់ទីតាំងសម្រាប់ការរួមភេទ "សេវានៃការរួមរាន[illegible]
បញ្ចូលក្នុងបុង" ។ នៅទីកន្លែងកើតហេតុសមត្ថកិច្ចក៏បានដកហូតបានស្រោមអនាម័យដែលប្រើរួច[illegible]
នេះតំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ[illegible]
ការដដែល ស្នើសុំឲ្យតុលាការពិនិត្យ និងសម្រេចទៅតាមច្បាប់ ។

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីខ្ញុំបានឆ្លើយនាពេលសវនាការនេះ ហើយ[illegible]
ឆ្លើយថាមិនមានការបង្ខិតបង្ខំអ្វីដែរ គឺពួកគាត់ទៅដោយស្ម័គ្រចិត្ត។ ដូច្នេះស្នើសុំឲ្យកូនក្តីខ្លួនរួចផុត[illegible]

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថា ៖ តាមកំណត់ហេតុនៅដំណាក់កាលមន្ត្រីយុត្តិធម៌[illegible]
អុលដាវី ឆ្លើយថា មិនស្គាល់កូនក្តីខ្លួននោះទេ [redacted] លីហ្សា, [redacted] សុផល, [redacted] ស្រីនាង។ ក្នុង[illegible]
មន្ត្រីនគរបាលយុត្តិធម៌ គឺកូនក្តីខ្ញុំមានតម្រុយ។ កូនក្តីបានប៉ះពាក់សម្តីជាមួយមន្ត្រីនគរបាលយុ[illegible]
អាចជាមូលហេតុផងដែរ។ ឃើញថា កូនក្តីជាចុងភៅមិនដែលទទួលលុយ១កាក់១សេននោះ[illegible]
ការណ៍ឯកត្តកម្មអ្នកណាធ្វើអ្នកនឹងទទួល។ មាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឃើញថា រឿង[illegible]
ស៊ើបសួរ បានសួរតែដាក់បន្ទុក។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ គឺរឹមតិសង្ឃឹយបានជាផលប្រយោ[illegible]
ស្នើសុំឲ្យកូនក្តីរួចផុតបទចោទ ដោយសារសមត្ថកិច្ចចាប់ខ្លួនកូនក្តីខ្ញុំតាមកំហឹង។

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថា៖ ការលើកឡើងថាកូនក្តីខ្ញុំបានប្រព្រឹត្ត គឺជនរងគ្រោះបាន
បញ្ជាក់ហើយ គឺយកពីខាងក្រៅទេ។ ម្យ៉ាងទៀតការបើក គឺបើកជាមុខរបររកកម្រៃ។ ពេលចូលដេងប្លាស់ហាង
មិនអាចមានសិទ្ធិសួរគេថាយកក្មេងមកធ្វើអ្វីនោះទេ ព្រោះពេលស្រវឹងគាត់មិនអាចបើកបរបាននោះទេ។ ប្លា
មួយទៀតមេការបានបញ្ជាក់ដែរថា អ្នកខ្លះគេមកពីក្រៅ មិនមែនជាបុគ្គលិករបស់ហាងទេ។ មិនមានអ្នកហាង
ចាប់បានថាក្មេងៗកំពុងផ្តល់សេវាផ្លូវភេទទេ។ សុំឲ្យកូនក្តីរួចផុតពីការចោទប្រកាន់។

-សំណូមពរចុងក្រោយរបស់ជនជាប់ចោទទាំងពីរ ៖ សូមឲ្យតុលាការមេត្តាជួយបន្ទូរបន្ទាប់[illegible]
លែងទៅផ្ទះវិញផង។

## សាលាដំបូងខេត្តកំពង់ស្ពឺ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ដែលវត្តមាន

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងសាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនរងគ្រោះ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពិនិត្យឯកសារនានាពាក់ព័ន្ធក្នុងសំណុំរឿង
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចមក

## សំអាងហេតុ

១/. ជនជាប់ចោទដែលមានវត្តមានបានបដិសេធចំពោះបទចោទប្រកាន់មកលើខ្លួន ហើយអះអាងថាទង្វើរបស់កុមារីរងគ្រោះគឺជាការប្រព្រឹត្តផ្ទាល់ខ្លួន មិនពាក់ព័ន្ធជាមួយពួកខ្លួននោះទេ។

ក៏ប៉ុន្តែដោយយោងលើភស្តុតាងជាចម្លើយរបស់សាក្សីជាកុមារីរងគ្រោះ បង្ហាញឲ្យឃើញថា ចំពោះជនជាប់ចោទឈ្មោះ [redacted] សុខខួច គឺសាក្សី ក៏ដូចជាសាមីខ្លួនជនជាប់ចោទបានបញ្ជាក់ថា បានទទួលប្រាក់ពីសាក្សីចំនួន១០$ ក្នុងម្តង (ជាលុយឲ្យចាយធម្មតា) តែតុលាការយល់ឃើញថា ជាលុយពាក់ព័ន្ធនឹងសព្វាវកម្មពីព្រោះក្នុងមួយលើក។ ដែលសាក្សីចេញជាមួយភ្ញៀវ ទោះបីទទួលបានពីភ្ញៀវ១០០$ ឬ២០០$ ក៏ដោយ ក៏ជនជាប់ចោទរូបនេះនៅតែទទួលបាន ១០$ដដែល (ថេរដដែល) មិនលើស មិនខ្វះ។

ចំពោះជនជាប់ចោទឈ្មោះ [redacted] ជាត វិញ សាក្សីឈ្មោះ [redacted] ណៃស៊ីម បានបញ្ជាក់ច្បាស់លាស់ហើយពីសកម្មភាពរបស់ជនជាប់ចោទរូបនេះ ដូចជា - នៅក្នុងហាងខ្លួនធ្លាប់ដឹងថា មីងឈ្មោះ ជាត [redacted] ជាត) ធ្លាប់ទទួលភ្ញៀវរួមភេទនៅក្នុងហាង (ផ្ទះសំណាក់) ពេលខ្លះមានភ្ញៀវទាក់ទងចង់បាននារីទៅរួមភេទតាមរយៈគាត់ ប៉ុន្តែខ្លួនមិនដឹងគាត់ឆ្លើយថាម៉េចទេ។ ប្រាក់សេវាកម្មផ្លូវភេទ ដែលខ្លួនទទួលបាន ខ្លួនយកទៅចាយវាយប្រចាំថ្ងៃ និងសម្រាប់ទុកចាយវាយពេលក្រោយ - ។

រីឯជនជាប់ចោទឈ្មោះ [redacted] ឆន្ធា ហៅ ម៉ាប់ គឺពុំមានចម្លើយរបស់ជននេះទេ ក៏ប៉ុន្តែអំពីភស្តុតាងដាក់បន្ទុកគឺមានស្ថានភាពដូចពន្យល់ខាងលើនេះដែរ។

២/. ចំពោះជនជាប់ចោទឈ្មោះ [redacted] សុងហាក់ តុលាការទទួលស្គាល់ដូចការសន្និដ្ឋានរបស់តំណាងអយ្យការដែរ អំពីភស្តុតាងដាក់បន្ទុក ជាអាទិ៍ (គិតលុយចូលក្នុងបុង ស្រោមអនាម័យ....)។

៣/. តាមសំអាងហេតុខាងលើ ឃើញថា មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើ

៣.១/ ជនជាប់ចោទឈ្មោះ [redacted] សុខខួច ភេទស្រី អាយុ ៣៧ឆ្នាំ, ឈ្មោះ [redacted] ជាត ភេទស្រី អាយុ ៣១ឆ្នាំ និងឈ្មោះ [redacted] ឆន្ធា ហៅ អាម៉ាប់ ភេទស្រី អាយុ ៣៧ឆ្នាំ ពីបទ សព្វាវកម្ម ប្រព្រឹត្តនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ទីតាំងស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៣.២/ ឈ្មោះ [redacted] សុងហាក់ ភេទប្រុស អាយុ ៣៧ឆ្នាំ ពីបទ ផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យចារ និងសព្វាវកម្ម ប្រព្រឹត្តនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ទីតាំងស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ មាត្រា ២៦ និងមាត្រា ៣២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។



Scanned with CamScanner

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១/.ផ្តន្ទាទោសលើជនជាប់ចោទ ៖

១.១/ ឈ្មោះ [redacted] **សុខខួច** ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ

១.២/ ឈ្មោះ [redacted] **ជាត** ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗចំនួន **០២(ពីរ)ឆ្នាំ** ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន **១០(ដប់)ខែ** ទោសសល់ពីនេះជាទោសព្យួរធម្មតា ពីបទ **សញ្ជាវកម្ម** ប្រព្រឹត្តនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ទីតាំងស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ , មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

**២/.** ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **គន្ធា** ហៅ **អាម៉ាប់** ភេទស្រី អាយុ ៣៧ឆ្នាំ ដាក់ពន្ធនាគារចំនួន **០២(ពីរ)ឆ្នាំ** ពីបទ **សញ្ជាវកម្ម** ប្រព្រឹត្តនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ទីតាំងស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**៣/.** ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សុងហាក់** ភេទប្រុស អាយុ ៣៧ឆ្នាំ ដាក់ពន្ធនាគារចំនួន **០២(ពីរ)ឆ្នាំ** ប៉ុន្តែទោសនេះជាទោសព្យួរធម្មតា ពីបទ **ផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យចារ និងសញ្ជាវកម្ម** ប្រព្រឹត្តនៅក្នុងភោជនីយដ្ឋាន និងផ្ទះសំណាក់ម្លប់ពោធិ៍រំលេចធំ ទីតាំងស្ថិតនៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ មាត្រា ២៦ និងមាត្រា ៣២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ, មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

៤/. រឹបអូសវត្ថុតាងទាំងអស់នៃសំណុំរឿងនេះ។

**៥/.** សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុខខួច** និងឈ្មោះ [redacted] **ជាត**។

- សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

*បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។*
ថ្ងៃ[illegible] ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តកំពង់ស្ពឺ, ថ្ងៃទី..៣០..ខែឧសភា ឆ្នាំ២០២៣

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner